# របាយការណ៍សង្ខេបវឌ្ឍនភាពគម្រោងអប់រំ
# របស់អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ
# ខែកញ្ញា ឆ្នាំ២០២៥

## I. សេចក្តីផ្តើម

អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ (ស៊ីថេប) ជាអង្គការក្រៅរដ្ឋាភិបាល ដែលបានបង្កើតក្នុងគោលបំណង និងគោលដៅ ដូចខាងក្រោម៖

**១. អំពីគោលបំណង**

- បណ្តុះបណ្តាលភាសាបរទេសនិងកុំព្យូទ័រដល់យុវជនខ្មែរនៅតាមទីជនបទដោយមិនបង់ថ្លៃសិក្សា
- បង្រៀននូវជំនាញបច្ចេកទេស វិជ្ជាជីវៈ ដល់សិស្ស និស្សិត ដែលគ្មានសមត្ថភាពបង់ថ្លៃសិក្សា
- ចូលរួមលើកទឹកចិត្តដល់សិស្ស និស្សិតក្នុងការបន្តការសិក្សា និងការអភិវឌ្ឍសមត្ថភាព ដើម្បីភាពជោគជ័យ
- ជួយជាសម្ភារសិក្សាដល់សិស្ស និស្សិត ដែលគ្មានលទ្ធភាព
- ជួយស្វែងរកការងារសមរម្យឲ្យដល់ប្រជាជនខ្មែរ ដើម្បីកាត់បន្ថយការចំណាកស្រុក និងចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិ។

**២. អំពីគោលដៅ**

- យុវជនមានចំណេះដឹងផ្នែកកុំព្យូទ័រ និងភាសាបរទេសច្បាស់លាស់ និងអាចប្រើប្រាស់ក្នុងការងារ
- ធ្វើឲ្យសិស្ស និស្សិតទទួលបានការអប់រំ និងមាននូវជំនាញវិជ្ជាជីវៈច្បាស់លាស់។

## II. វឌ្ឍនភាពគម្រោងអបរំ

### ១. របាយការណ៍ត្រីមាសទី៣ឆ្នាំ២០២៥

ក្នុងគម្រោងអប់រំ អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ (ស៊ីថេប) កំពុងសហការជាមួយនឹងមណ្ឌលសិក្សាសហគមន៍ចំនួន ១០ និង វិទ្យាល័យចំនួន៨ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៥។ ដោយយើងផ្តល់ជូននូវវគ្គសិក្សាថ្នាក់ភាសាអង់គ្លេស ចិន កុំព្យូទ័រ និងថ្នាក់សរសេរកូដ។

ក្នុងត្រីមាសនេះយើងមានមណ្ឌលសិក្សាសហគមន៍ បានបញ្ចប់វគ្គសិក្សា ហើយយើងបានដាក់បញ្ចូលនូវទិន្នន័យខាងក្រោម។ នៅឡើយតែថ្នាក់កុំព្យូទ័រនៅតាមវិទ្យាល័យដែលមិនទាន់បានបញ្ចប់ ហើយយើងនឹងធ្វើបច្ចុប្បន្នភាពនៅត្រីមាសបន្ទាប់។

| ថ្នាក់ | | លទ្ធផលវគ្គនេះ 30.09.2025 | | សរុបរួម ( 2025.09.30 ) | | ចុះឈ្មោះវគ្គថ្មី ( 2025.09.30 ) | |
|---|---|---|---|---|---|---|---|
| | | ចុះឈ្មោះ | បញ្ចប់ | ចុះឈ្មោះ | បញ្ចប់ | ចំនួនថ្នាក់ | ចំនួនសិស្ស |
| សហគមន៍ | កុំព្យូទ័រ | 821 | 574 | 26106 | 15524 | 38 | 1034 |
| | អង់គ្លេស | 1836 | 1230 | 48860 | 28226 | 53 | 1636 |
| | ចិន | 0 | 0 | 1934 | 1162 | 0 | 0 |
| | ថ្នាក់កូដ | 680 | 448 | 2536 | 1209 | 24 | 656 |
| វិទ្យាល័យ | កុំព្យូទ័រ | 0 | 0 | 34776 | 16112 | 87 | 3581 |
| | អង់គ្លេស | 0 | 0 | 2666 | 1689 | 0 | 0 |
| | ថ្នាក់កូដ | 0 | 0 | 3297 | 2064 | 42 | 1163 |
| | សរុប | **3337** | **2252** | **120175** | **65986** | **244** | **8070** |

### ២. លទ្ធផលមណ្ឌលសិក្សាសហគមន៍

មានមណ្ឌលសិក្សាជាច្រើនបានបញ្ចប់វគ្គ និងរៀបចំកម្មពិធីបិទវគ្គ ប្រគល់វិញ្ញាបនបត្រក្នុងខែសីហាឆ្នាំ២០២៥។ ដោយយោងតាមលទ្ធផលនេះ មានសិស្ស៦៣% បានប្រឡងជាប់ និង២៣.៥% ធ្លាក់ (រៀនត្រួតថ្នាក់)។ ដោយឡែកមាន ១៥% ផ្សេងទៀតបានបោះបង់ការសិក្សា ព្រោះមូលហេតុភារកិច្ចគ្រួសារ និងសាលា។

| លទ្ធផលសិក្សា (ខែកុម្ភៈ ដល់ ខែសីហា ២០២៥) | | | | | | |
|---|---|---|---|---|---|---|
| ល.រ | មណ្ឌលសិក្សា | វគ្គសិក្សា | ចុះឈ្មោះ | បោះបង់ | ជាប់ | ធ្លាក់ |
| 1 | ដានរុន | 35 | 202 | 51 | 112 | 39 |
| 2 | គោល | 29 | 220 | 23 | 162 | 35 |
| 3 | កំពង់ស្វាយ | 23 | 196 | 18 | 102 | 76 |
| 4 | ប្រាសាទធ្នង់ | 22 | 375 | 21 | 292 | 62 |

| | | | | | | |
|---|---|---|---|---|---|---|
| 5 | ស្ទឹងព្រះស្រុក | 33 | 504 | 68 | 293 | 143 |
| 6 | តាយ៉ែក | 33 | 340 | 35 | 267 | 38 |
| 7 | ថ្នល់ | 33 | 354 | 35 | 247 | 72 |
| 8 | តាស្នែ | 36 | 272 | 50 | 160 | 62 |
| 9 | រកា | 4 | 318 | 40 | 176 | 102 |
| 10 | ប្រវ៉ាល | 3 | 265 | 16 | 232 | 17 |
| | | សរុប: | **3046** | **357** | **2043** | **646** |

រាល់កម្មវិធីបិទវគ្គ និងប្រគល់វិញ្ញាបនបត្រ តែងតែមានការអញ្ជើញចូលរួមពីភាគីពាក់ព័ន្ធ ដូចជា សិស្ស អាណាព្យាបាលអាជ្ញាធរមូលដ្ឋាន លោកគ្រូអ្នកគ្រូ និងនាយកសាលាជាដើម។ ហេតុនេះហើយទាំងអស់គ្នាអាចជជែកពីបញ្ហា និងដំណោះស្រាយផ្សេងៗផងដែរ។

**៣. ទិន្នន័យសិស្សចុះឈ្មោះវគ្គសិក្សាថ្មី**

ដោយយើងបានធ្វើការផ្លាស់ប្តូរកម្មវិធីសិក្សាថ្មីអស់រយៈពេលបីវគ្គហើយនោះ យើងបានទទួលបានបទពិសោធន៍ លទ្ធផល និងមតិកែលម្អជាច្រើន។ ជាចុងក្រោយយើងបានធ្វើការកែសម្រួល និងទទួលបានសិស្សចុះឈ្មោះចូលរៀនច្រើនជាមុន ហើយប្រកបដោយគុណភាព។

**ការកែសម្រួលគោលការចុះឈ្មោះ:**

- កំណត់ចំនួនសិស្សក្នុងថ្នាក់: កុំព្យូទ័រ (20 - 30) អង់គ្លេស (25 - 35)
- ផ្តល់ទិន្នន័យច្បាស់លាស់ (ឈ្មោះជាភាសាអង់គ្លេស, អាសយដ្ឋាន, និងលេខទំនាក់ទំនង)
- តាមដានរាល់សិស្សដែលអវត្តមានច្រើន ហើយដាក់ចូលបញ្ជីខ្មៅ
- ត្រៀមសម្រាប់ការបង់វិភាគទានចូលរៀន នៅវគ្គសិក្សាបន្ទាប់

ទាំងអស់នេះមិនត្រឹមតែបានជួយសម្រួលដល់ការគ្រប់គ្រងរបស់គ្រូ និងថ្នាក់គ្រប់គ្រងទេ តែវាក៏បានធ្វើឲ្យសិស្សប្រឹងប្រែងសិក្សា និងចូលរួមកាន់តែច្រើនឡើង។

| សិស្សចុះឈ្មោះវគ្គសិក្សាថ្មី (ខែសីហា ២០២៥ ដល់ ខែកុម្ភៈ ២០២៦) | | | | | |
|---|---|---|---|---|---|
| ល.រ | មណ្ឌលសិក្សា | អង់គ្លេស | កុំព្យូទ័រ | ថ្នាក់កូដ | សរុប |
| 1 | ដានរុន | 95 | 100 | 50 | 245 |
| 2 | គោល | 94 | 103 | 25 | 222 |
| 3 | កំពង់ស្វាយ | 221 | 164 | 0 | 385 |
| 4 | ប្រាសាទផ្ចង់ | 211 | 111 | 58 | 380 |
| 5 | ស្ទឹងព្រះស្រុក | 279 | 118 | 164 | 625 |
| 6 | តាយ៉ែក | 168 | 152 | 54 | 374 |

| | | | | | |
|---|---|---|---|---|---|
| 7 | ថ្នល់ | 171 | 75 | 75 | 321 |
| 8 | តាស្ដែ | 140 | 86 | 57 | 283 |
| 9 | រកា | 193 | 0 | 148 | 341 |
| 10 | ប្រវ៉ាល | 0 | 125 | 25 | 150 |
| សរុបៈ | | **1636** | **1034** | **656** | **3326** |

### ៤. កំណើនសិស្សក្នុងថ្នាក់កូដ

ថ្នាក់កូដបានក្លាយជាថ្នាក់ពេញនិយម បន្ទាប់ពីការចាប់ផ្ដើមយ៉ាងលំបាកកាលពីពីរឆ្នាំមុន។ គ្រូៗទទួលបានការបណ្ដុះបណ្តាលពីអ្នកគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា និងការតាមដានរាល់លទ្ធផលសម្រេចបាន។ តាមរយៈគម្រោង តាមការបង្ហាញក្នុងមណ្ឌលសិក្សា រហូតដល់ការបង្ហាញទៅកាន់វេទិកាថ្នាក់ជាតិ ក្លាយជាកូនសោមួយជួយពួកគេប្រឹងប្រែងខ្លាំងឡើង។ ដូច្នេះហើយនៅក្នុងវគ្គសិក្សានេះមានសិស្សចុះឈ្មោះចូលរៀនច្រើន ទាំងមណ្ឌលសហគមន៍ និងវិទ្យាល័យ។

| | វគ្គសិក្សាមុន (សីហា២០២៤ ដល់កុម្ភៈ២០២៥) | | | វគ្គសិក្សានេះ (កុម្ភៈ ដល់សីហា ២០២៥) | | |
|---|---|---|---|---|---|---|
| មណ្ឌលសិក្សា | ថ្នាក់ | ចុះឈ្មោះ | បញ្ចប់ | ថ្នាក់ | ចុះឈ្មោះ | បញ្ចប់ |
| សហគមន៍ | 12 | 261 | 140 | 25 | 648 | 448 |
| វិទ្យាល័យ | 25 | 684 | 640 | 42 | 1163 | 0 |
| សរុប: | **54** | **945** | **780** | **67** | **1811** | **448** |

### មណ្ឌលសិក្សាថ្មីនៅវិទ្យាល័យ នរគធំនឹងចាប់ដំណើរការថ្នាក់កូដ

វិទ្យាល័យ នរគធំ បានចាប់ផ្ដើមសាកល្បងវគ្គសិក្សាថ្នាក់កូដ ពីខែកក្កដា ឆ្នាំ២០២៥មក ហើយនឹងត្រៀមសម្រាប់ការបើកថ្នាក់ផ្លូវការនៅឆ្នាំសិក្សាថ្មី (២០២៥ - ២០២៦)។ ថ្មីៗនេះមានសិស្សមួយក្រុម (២០នាក់)កំពុងសិក្សា ហើយគ្រូកំពុងត្រៀមសម្រាប់វគ្គសិក្សាថ្មី និងសម្ភារៈដែលពាក់ព័ន្ធ។

## III. បញ្ហាប្រឈម និងដំណោះស្រាយ

១. បញ្ហាប្រឈម

- ផលប៉ះពាល់នៃការកំណត់ថ្នាក់ថ្មីនឹងកើតឡើងនៅវគ្គសិក្សាថ្មីធ្វើឲ្យសិស្សត្រូវស្ថិតក្នុងបញ្ជីរង់ចាំសិន។ ជាមួយគ្នាផងដែរ មណ្ឌលសិក្សាខ្លះត្រូវការគ្រូបន្ថែមដើម្បីសម្រួលដល់ថ្នាក់ដែលរង់ចាំផងដែរ។
- ចំនួនសិស្សចាស់តាមថ្នាក់ថយចុះតិចជាងចំនួនកំណត់អប្បរមា។

- ការឱ្យសិស្សចូលរួមវិភាគទាននៅវគ្គសិក្សាថ្មីអាចជាបញ្ហាសម្រាប់សិស្សមួយចំនួនដែលមានកម្រិតជីវភាពទាប និងគ្រួសារដែលមានសមាជិកច្រើនមករៀន។
- ថ្នាក់កូដដំណើរការល្អ និងមានការចូលរួមពីគ្រូ និងសិស្ស ប៉ុន្តែបញ្ហាសម្ភារជំនួយនៅមានកម្រិតដោយត្រូវចំណាយថវិកាទិញពីក្រៅប្រទេស។

២. ដំណោះស្រាយ

- យើងព្យាយាមជ្រើសរើសគ្រូថ្មីមកជួយបង្រៀន និងមានការដាក់បញ្ចូលថ្នាក់ដែលអាចរៀនជាមួយគ្នាបាន។
- សម្រាប់ថ្នាក់សិស្សចាស់ ការបញ្ចូលវគ្គសិក្សាភាសាអង់គ្លេសដែលត្រូវកម្រិត និងម៉ោងដូចគ្នា។ សម្រាប់ថ្នាក់កុំព្យូទ័រ និងកូដអាចរៀនជាមួយគ្នាបានដោយការប្រឡងកំណត់តាមមុខវិជ្ជាជាក់ស្តែង។
- ការយកថ្លៃសិក្សាអនុវត្តចំពោះសិស្សក្រីក្រជាក់ស្តែង សិស្សដែលមានបងប្អូនច្រើនមករៀន និងសិស្សដែលទទួលបាននិទ្ទេសល្អ។
- យើងព្យាយាមប្រើប្រាស់សម្ភារដែលមានក្នុងស្រុក ឬបង្កើតការច្នៃប្រតិដ្ឋ និងសន្សំសំចៃ។ សម្រាប់ឧបករណ៍ចាំបាច់មួយចំនួនត្រូវបានចំណាយថវិកាទិញដោយស៊ីថេប។

IV. ទិសដៅ និងវិធានការណ៍

| **ទិសដៅ** | **វិធានការណ៍** |
|---|---|
| - កាត់បន្ថយអវត្តមាននិងការបោះបង់ការសិក្សារបស់សិស្ស | - ជំរុញលើកទឹកចិត្តសិស្សឲ្យយល់ពីសារប្រយោជន៍នៃភាសាអង់គ្លេសនិងកុំព្យូទ័រ ព្រមទាំងបំផុសចលនាមហាជនឲ្យចូលរួមតាមដានសកម្មភាពសិក្សារបស់កូនៗ |
| - បណ្តុះបណ្តាលបន្ថែមដល់គ្រូនៅតាមមូលដ្ឋាន | - ស្វែងរកដៃគូដើម្បីបញ្ជូនគ្រូទៅសិក្សាបន្ថែម និងបំប៉នគ្រូមួយដងក្នុងមួយខែរាល់ចុងសប្តាហ៍ |
| - ដំឡើងអ៊ីនធឺណិតនៅគ្រប់មណ្ឌលសិក្សា | - ជាការបង្កភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវរបស់គ្រូ និងសិស្ស |
| - បន្តការជួយឧបត្ថម្ភកុំព្យូទ័រដល់សាលាចំណេះទូទៅ និងបច្ចេកទេស | |

| | |
|---|---|
| | - សហការជាមួយនាយកដ្ឋានតម្រង់ទិសនិងវិជ្ជាជីវៈនៃក្រសួងអប់រំ ដើម្បីកំណត់សាលាអាទិភាព |

## V. សន្និដ្ឋាន

ទោះបីជាការចូលរៀនរបស់សិស្សមានចំនួនកើន តែកត្តាបោះបង់ និងការចូលរួមពីអាណាព្យាបាលនៅមានកម្រិត ហើយយើងបានព្យាយាមដោយអស់ពីសមត្ថភាព ដោយការធ្វើសកម្មភាពដោះស្រាយបញ្ហាជាក់ស្តែង ។ មិនតែប៉ុណ្ណោះ យើងនៅបន្តលើកទឹកចិត្តឱ្យសិស្សានុសិស្សរក្សាទំនាកទំនងល្អជាមួយគ្រូសម្រាប់ការរៀបចំថ្នាក់រៀននៅវគ្គថ្មី។ ចំពោះសិស្សដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ យើងបានជួបជជែក និងផ្តល់ប្រឹក្សាសម្រាប់ការជ្រើសរើសការបន្តការសិក្សា ឬស្វែងរកការងារផងដែរ។

## VI. រូបថតសកម្មភាពរបស់អង្គការ

**សកម្មភាពបិទវគ្គសិក្សា និងប្រគល់វិញ្ញាបនបត្រដល់សិស្សានុសិស្ស**






**សកម្មភាពចុះឈ្មោះ និងណែនាំអំពីស៊ីថេប**





## សកម្មភាពរៀននិងបង្រៀននៅតាមមណ្ឌលសិក្សា









## សកម្មភាពប្រជុំនិងបំប៉នគ្រូបន្ថែម















វិទ្យាល័យនគរធំ
Nokorthom High School

